00378060

E159/3

០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ង

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 17 / 09 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**សេចក្តីលម្អិតអំពីការដាក់ជូន**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជសដ |
| កាលបរិច្ឆេទ | : | ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ |
| ភាគីដាក់ជូនសារណា | : | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន | : | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម | : | ភាសាអង់គ្លេស |

**ចំណាត់ថ្នាក់**

| | | |
|---|---|---|
| ចំណាត់ថ្នាក់ឯកសារដែលស្នើសុំដោយភាគីដាក់ឯកសារ | : | សាធារណៈ |
| ចំណាត់ថ្នាក់ដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ | : | |
| ស្ថានភាពចំណាត់ថ្នាក់ | : | |
| ការពិនិត្យឡើងវិញលើចំណាត់ថ្នាក់បណ្តោះអាសន្ន | : | |
| ឈ្មោះមន្ត្រីកត់ត្រា | : | |
| ហត្ថលេខា | : | |

---

# សារណារួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីសំណង

---

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA


**ដាក់ជូនដោយ:**
**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក Karim A.A. KHAN
កញ្ញា ទី ស្រីនណា
លោក Alain WERNER
លោកស្រី Brianne McGONIGLE


Original EN: 00375447-00375465

00378061

E159/3

០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ជូនចំពោះ:**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

លោក Pierre-Oliver SUR
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យុង ផានិត
លោកស្រី Silke STUDZINSKY
លោក គឹម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី Christine MARTINEAU
លោកស្រី Fabienne Trusses NAPROUS
លោកស្រី Annie DELAHAIE
លោកស្រី Elisabeth RABESANDRATA NA

**ចម្លងជូន:**

**ជនជាប់ចោទ:**

លោក កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ:**

លោក ការ សាវុត្ថ
លោក François ROUX

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង
លោក យ៉េត ចរិយា
លោក William SMITH
លោក ពេជ្រ សម្បត្តិ

Original EN: 00375447-00375465

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល ដែលស្នើឱ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណា "ដែលបញ្ជាក់ពីទម្រង់ នៃការទាមទារសំណងផ្លូវចិត្ត និងសំណងសមូហភាពប្រឆាំងនឹងជនជាប់ចោទ ប្រសិនបើត្រូវបានផ្តន្ទាទោស[1]"។

២. យោងតាមវិធានផ្ទៃក្នុង គោលបំណងមួយនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺដើម្បី "អនុញ្ញាតឱ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសមូហភាព...[2]"។ ក្នុងបរិបទនៃអំពើហិង្សាទ្រង់ទ្រាយធំ និងការរំលោភបំពានដោយកំរោលលើច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌ ច្បាប់អន្តរជាតិបានផ្តល់មូលដ្ឋានដល់ជនរងគ្រោះដើម្បីទាមទារសំណង ហើយកាន់តែទទួលស្គាល់ខ្លាំងឡើងថាការស្វែងរកសំណងគឺជាសិទ្ធិមួយ[3]។ ជាទូទៅពាក្យថា"សំណង"ក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ គឺសំដៅទៅដល់ការឆ្លើយតបទៅនឹងព្យសនកម្ម ដែលជនរងគ្រោះបានទទួលរងពីការរំលោភបំពានជាលក្ខណៈទ្រង់ទ្រាយធំ និងធ្ងន់ធ្ងរ។ សំណងជាយន្តការចាំបាច់មួយដើម្បីឱ្យគេទទួលស្គាល់

---

[1] *រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ, សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, កថាខណ្ឌ១។

[2] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ២៣(១)(ខ)។

[3] សិទ្ធិទទួលបានសំណងត្រូវបានឆ្លុះបញ្ចាំងក្នុងកិច្ចព្រមព្រៀងអន្តរជាតិជាច្រើនរួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងអនុសញ្ញាផ្សេងទៀត។ កាតព្វកិច្ចនេះ ត្រូវបានបញ្ជាក់អនុម័តដោយមហាសន្និបាទអង្គការសហប្រជាជាតិ នៃគោលការណ៍និងសេចក្តីណែនាំជាមូលដ្ឋានស្តីពីសិទ្ធិទទួលបានការព្យាបាលនិងសំណងចំពោះការរំលោភយ៉ាងកំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងការរំលោភធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ, C.H.R. res. 2005/35, U.N. Doc. E/CN.4/2005/ L.10/Add.11 (ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥) [*បន្ទាប់ពីនេះយោងដោយ* "គោលការណ៍មូលដ្ឋាន"]។

សិទ្ធិជនរងគ្រោះ និងដឹងអំពីព្យសនកម្មដែលជនរងគ្រោះបានទទួលរង ក៏ដូចជាស្តារតម្លៃ និងសេចក្តីថ្លៃថ្នូររបស់ពួកគាត់ឡើងវិញនៅក្នុងសង្គម[4]។

៣. បើទោះបីជាវិធានផ្ទៃក្នុងពិតជាបានកំណត់ព្រំដែនលើទម្រង់នៃសំណង សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្តី ក៏វាជាការចាំបាច់ដែលដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ត្រូវទទួលបានសំណងផ្លូវចិត្ត និងសមូហភាពដែលប្រកបទៅដោយអត្ថន័យ និងសារសំខាន់[5]។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីសូមអះអាងដោយសេចក្តីគោរពថា តុលាការនេះមានសិទ្ធិអំណាចផ្តល់ជាសំណងផ្លូវចិត្ត និងសមូហភាពប្រកបដោយអត្ថន័យជាច្រើនយ៉ាង ប៉ុន្តែពុំកំណត់ត្រឹមតែសំណងទាំងប៉ុន្មានខាងក្រោមនេះទេ។ សំណងទាំងនោះរួមមានដូចជា៖ ការផ្សព្វផ្សាយព័ត៌មាន និងការសូមអភ័យទោសពីជនជាប់ចោទ ប្រសិនបើត្រូវបានផ្តន្ទាទោស ការថែទាំវេជ្ជសាស្ត្រ រួមមានការថែទាំផ្លូវកាយ និងផ្លូវចិត្ត កម្មវិធីសិក្សាអប់រំ និងការធ្វើពិធីរម្លឹកដល់ជនគ្រោះ[6]។

៤. លើសពីនេះ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយសេចក្តីគោរពថាប្រសិនបើជនជាប់ចោទត្រូវបានតុលាការផ្តន្ទាទោសក៏ប៉ុន្តែគ្មានលទ្ធភាពសងសំណង នោះតុលាការត្រូវ(១) ជម្រុញលើកទឹកចិត្តរដ្ឋាភិបាលកម្ពុជា ឱ្យបង្កើតកម្មវិធីសំណងមួយដែលរដ្ឋជាអ្នកចេញថវិកាឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះ ហើយ(២) ត្រូវបង្កើតមូលនិធិពិសេសស្ម័គ្រចិត្តមួយក្នុងតុលាការដែលអាចដឹកនាំដោយអង្គភាពជនរងគ្រោះ ឬស្ថាប័នផ្សេងទៀតដើម្បីចាត់ចែងថវិកា។ ក្នុងចំណោមមូលនិធិពិសេសទាំងពីរនេះ ប្រសិនបើគេបង្កើតចេញ

---

4 Lisa Magarrell, *សំណងជាទ្រឹស្តី និងការអនុវត្តន៍,* មជ្ឈមណ្ឌលអន្តរជាតិសម្រាប់អន្តរយុត្តិធម៌, www.ictj.org/static/Reparations/0710.Reparations.pdf ចូលទស្សនាចុងក្រោយនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៩។

5 យោងតាមលទ្ធផលនៃការស្ទង់ដែលធ្វើឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្ស នៅឯសកលវិទ្យាល័យ California នៅ Berkeley, បង្ហាញថាចំនួន៨៨ភាគរយ នៃអ្នកឆ្លើយតបទាំងអស់ជឿថាការផ្តល់ឱ្យនូវសំណងផ្លូវចិត្ត ឬសំណងនិមិត្តរូបមានសារសំខាន់ ហើយចំនួន៦៨ភាគរយ ជឿថាសំណងគួរមានគុណៈជាសំណងរួម។ សូមមើល Phuong Pham, Patrick Vinck, Mychelle Balthazard, Sokhom Hean និង Eric Stover ក្នុងអត្ថបទមានចំណងជើងថា *So We Will Never Forget* បោះពុម្ពដោយ University of California Berkeley Human Rights Center (ខែមករា ឆ្នាំ២០០៩) ទំព័រ៤៣-៤៤។

6 ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បន្តស្នើថាតុលាការមានអំណាចស្នើសុំការទទួលស្គាល់ជាផ្លូវការ និងការសុំទោសពីរដ្ឋាភិបាលកម្ពុជា។

ជារូបរាងពិតប្រាកដមែន មួយណាក៏បានគឺសុទ្ធតែអាចមានលទ្ធភាពសងសំណងដែលតុលាការបានប្រកាសឱ្យសងបានទាំងអស់។

## II. លក្ខណៈ និងគោលដៅនៃសំណង

៥. គោលបំណងសំខាន់ៗនៃកម្មវិធីសងសំណង ក្នុងបរិបទនៃការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌ ជាទូទៅមានដូចជា ការប្រគល់មកវិញ ការសងការខូចខាត ការស្តារនីតិសម្បទារ ការប៉ះប៉ូវ និងការធានាមិនឱ្យមានការកើតឡើងសារជាថ្មី[7]។ ការប្រគល់មកវិញ មានន័យថាដាក់ជនរងគ្រោះឱ្យស្ថិតក្នុងសភាពដើម មុនពេលនៃការកើតមានអំពើហិង្សា[8]។ ការសងការខូចខាតគឺសមល្មមនឹងធ្វើទៅលើការខូចខាតដែលអាចប៉ាន់ស្មានជាទឹកប្រាក់បាន តួយ៉ាងដូចជាព្យសនកម្មផ្លូវកាយ និងផ្លូវចិត្ត ឱកាសដែលបាត់បង់ដូចជាការងារ ការខូចខាតសម្ភារៈ និងការបាត់បង់ការរកប្រាក់ចំណូល ការខូចខាតផ្លូវចិត្ត និងសោហ៊ុយទៅលើសេវាវេជ្ជសាស្ត្រ ផ្លូវច្បាប់ និងសង្គម ជាដើម[9]។ ការប៉ះប៉ូវ ជាទូទៅសំដៅទៅដល់វិធានការច្រើនយ៉ាងដែលក្នុងនោះរួមមាន ការបញ្ឈប់អំពើហិង្សា ការលាតត្រដាងឱ្យសាធារណជនទូទៅបានដឹងអំពីការពិត ការស្វែងរកទីកន្លែងមនុស្សបាត់ខ្លួន ។ល។ ការសូមអភ័យទោសជាសាធារណៈ ទណ្ឌកម្មប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះអំពើហិង្សា ការរម្លឹកអំពីជនរងគ្រោះ និងការបង់វិភាគទានឱ្យជនរងគ្រោះ[10]។ ចុងក្រោយ ការធានាមិនឱ្យមានអំពើហិង្សាកើតឡើងសារជាថ្មី គឺនិយាយសំដៅទៅដល់វិធានការច្រើនយ៉ាងក្នុងការទប់ស្កាត់ការកើតឡើងជាថ្មីនៃអំពើហិង្សា រួមមានដូចជាវិធានការពង្រឹងវិធាននៃច្បាប់ និងការគោរពតាមនិយាមច្បាប់ និងសីលធម៌ របស់ស្ថាប័នក្នុងស្រុកជាដើម។

---

[7] Jaya Ramji, "ការឆ្លើយតបជារួមមួយ ទៅនឹងអំពើហិង្សាទ្រង់ទ្រាយធំ៖ សំណងនិងការផ្សះផ្សាក្នុងប្រទេសកម្ពុជា" ក្នុងសៀវភៅរបស់ Jaya Ramji និង Beth Van Schaack, *ការនាំខ្មែរក្រហមមកកាត់ទោស៖ ការកាត់សេចក្តីអំពើហិង្សាទ្រង់ទ្រាយធំនៅមុខតុលាការកម្ពុជា* (២០០៥), ទំព័រ ៣៦០។

[8] M. Cherif Bassiouni, *ការទទួលស្គាល់សិទ្ធិជនរងគ្រោះជាអន្តរជាតិ*, ព្រឹត្តិប័ត្រច្បាប់សិទ្ធិមនុស្សលេខ៦ ទំព័រ២០៣, ២៦៨ (២០០៦)។

[9] *ដូចជើងទំព័រខាងលើ* ត្រង់ទំព័រ២៧០។

[10] *ដូចជើងទំព័រខាងលើ* ត្រង់ទំព័រ២៧២។

៦. គោលដៅនៃកម្មវិធីសងសំណង គឺវានឹងអាស្រ័យទៅតាមកាលៈទេសៈនៃការរំលោភសិទ្ធិមនុស្ស និងលក្ខណៈនៃសង្គមដែលបានទទួលរងការប៉ះពាល់។ បន្ទាប់មក គោលដៅទាំងអស់នេះនឹងកំណត់ថាតើទម្រង់នៃសំណងណាមួយសមរម្យ ពោលគឺតើវាគួរជាសំណងហិរញ្ញវត្ថុ ជាការស្តារសិទ្ធ ផ្លូវចិត្ត សង្គម ឬក៏ជាការច្របាច់បញ្ចូលគ្នានៃមធ្យោបាយខុសៗគ្នា។ បន្ថែមពីលើចំណុចនេះ គោលដៅទាំងអស់នេះនឹងកំណត់ថាតើយន្តការនៃការសងសំណងមួយណាដែលស័ក្តិសមបំផុតដែលគួរជាសំណងបុគ្គល ឬមួយសំណងសមូហភាព។

៧. ជាទូទៅ សំណងអាចសំដៅទៅដល់សំណងជាបុគ្គល ឬជាសមូហភាព។ បើទោះបីជាក្នុងគ្រានេះ សំណងបុគ្គលពុំស្ថិតក្នុងយុត្តាធិការតុលាការនេះក្តី ក៏មានដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចបានដាក់ពាក្យសុំរួចទៅហើយ ហើយសំណងបុគ្គលនេះអាចមានលទ្ធភាពជួយសងព្យសនកម្មដែលពួកគាត់បានទទួលរង។ សំណងសមូហភាព ដែលជាទម្រង់តែមួយគត់នៃសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននៅចំពោះមុខតុលាការនេះផ្តោតទៅលើការផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះ ដែលបានរងគ្រោះដោយផ្ទាល់ ឬប្រយោលពីការរំលោភសិទ្ធិមនុស្ស ជាក្រុម។ ក្រោយពីសង្គមក្នុងគ្រាក្រោយហឹង្សាទ្រង់ទ្រាយធំបានបញ្ចប់ទៅ សំណងសមូហភាពគឺជាការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពដល់ការសងការខូចខាតខាងផ្លូវចិត្ត អត្តសញ្ញាណ និងទំនុកចិត្តរបស់សង្គម ឬក្រុមជនរងគ្រោះ។ សំណងសមូហភាពជួយព្យាបាលរួម និងបង្កើតឱ្យមានស្មារតីសាមគ្គីភាពនិងឯកភាពក្នុងចំណោមដើមបណ្តឹង រដ្ឋប្បវេណីក្នុងសំណុំរឿងនេះ។ សំណងសមូហភាពក៏ជួយប៉ះប៉ូវការខូចខាតជាក់ស្តែង នៃហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងស្ថាប័នទៀតផង។

## III. វិសាលភាពនៃវិធាន២៣

៨. អំណាចក្នុងផ្តល់សំណងរបស់ អ.វ.ត.ក មាននៅក្នុងវិធាន២៣(១១) នៃវិធានផ្ទៃក្នុង[11]។ បទបញ្ញត្តិនេះអនុញ្ញាតឱ្យជនរងគ្រោះអាចទាមទារសំណង តាមការបង្ហាញខ្លួនជាផ្លូវការ

[11] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ដូចដែលត្រូវបានពិនិត្យឡើងវិញនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩។

តាមរយៈ "បណ្ដឹងរដ្ឋប្បវេណី" តែប៉ុណ្ណោះ ហើយក៏កំណត់ប្រភេទនៃសំណងដែលតុលាការផ្ដល់ឱ្យ "សំណងផ្លូវចិត្ត និងសមូហភាព"។

៩. មាត្រា២៣(១២) បញ្ជាក់ទៀតថាទម្រង់នៃ "សំណងផ្លូវចិត្ត និងសមហូភាព" អាចរួមមានដូចជាការបញ្ជាទណ្ឌិតឱ្យ "បោះផ្សាយសាលក្រមតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗណាមួយដែលសមរម្យ" "ផ្ដល់ថវិកាទៅដល់សកម្មភាពមិនរកប្រាក់ចំណេញ ឬសេវាដែលបម្រើដល់ប្រយោជន៍ជនរងគ្រោះ" ឬ "ទម្រង់នៃសំណងផ្សេងៗដែលសមមូល និងសមរម្យ"។ ឧទាហរណ៍ទាំងអម្បាលម៉ាននេះទុកឱកាសឱ្យតុលាការអនុវត្តភាពអាចបត់បែនបានក្នុងការផ្ដល់សំណងជាក់ស្ដែង ដូចជាតាមរយៈការបញ្ជាឱ្យទណ្ឌិតបម្រើសេវាសហគមន៍ ឬដែលគេអាចបកស្រាយបានថាជាការបង្ហាញខ្លួននៅចំពោះមុខសហគមន៍ ជាជាងការពឹងផ្អែកតែទៅលើប្រព័ន្ធផ្សព្វផ្សាយទូទៅដែលមិនអាចទៅដល់ជនរងគ្រោះ[12]។

១០. សំណងផ្លូវចិត្ត និងសមូហភាពផ្សេងៗរួមមាន ការកសាងបូជនីយដ្ឋានសាធារណៈ និងរូបសំណាក ការជម្រុញលើកទឹកចិត្តរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើតឱ្យមានថ្ងៃនៃការចងចាំ ការកំណត់អត្តសញ្ញាណ និងការបញ្ចុះសពជនរងគ្រោះ ឬការរម្លឹកដល់ជនរងគ្រោះ ការចេញផ្សាយសេចក្ដីសូមអភ័យទោសជាសាធារណៈរបស់ទណ្ឌិត ការបង្កើត ឬការជួយឧបត្ថម្ភគាំទ្រមជ្ឈមណ្ឌលវេជ្ជសាស្ត្រ និងគ្លីនិកប្រឹក្សាយោបល់ ការកសាង ឬការជួយឧបត្ថម្ភគាំទ្រសាលារៀន និងកម្មវិធីសិក្សាអប់រំផ្សេងៗ និងទម្រង់នៃការរម្លឹកផ្សេងៗដែលចាំបាច់សម្រាប់ជនដែលរងគ្រោះដោយផ្ទាល់និងដោយប្រយោល។ សាធារណជនដែលជាធាតុផ្សំមួយក្នុងសកម្មភាពទាំងអស់នេះ មានសារសំខាន់ដែលនាំទៅដល់ការទទួលស្គាល់ពីសង្គមកាន់តែទូលំទូលាយ ដែលវាដើរតួនាទីសំខាន់ក្នុងការដោះស្រាយបញ្ហាការផាត់ចេញពីសង្គម និងព្យសនកម្មដែលជនរងគ្រោះបានទទួលរង។

---

[12] Ruben Carranza, *ទឹកតិតដល់លទ្ធភាពសម្រាប់សំណងនៅប្រទេសកម្ពុជា*, មជ្ឈមណ្ឌលអន្តរជាតិសម្រាប់អន្តរយុត្តិធម៌, http://www.ictj.org/imagines/content/9/5/950.pdf (ចូលទស្សនចុងក្រោយនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៨)។ Lasa Magarell, *យោងខាងលើ*, កំណត់សម្គាល់ទី២, ទំព័រ៥។

## IV. ទម្រង់នៃសំណងផ្លូវចិត្តនិងសំណងសមូហភាពដែលបានស្នើសុំ

១១. ផ្អែកតាមព័ត៌មានដែលទទួលបានពីគ្រប់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈទម្រង់ពាក្យសុំដំបូងរបស់ពួកគាត់និងការប្រជុំពិភាក្សាជាបន្តបន្ទាប់រួចមក សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើឱ្យតុលាការផ្តល់សំណង ដែលគិតទៅដល់ព្យសនកម្ម ដែលបានទទួលរងកន្លងមក ព្យសនកម្មដែលកំពុងទទួលរង និងបរិបទវប្បធម៌ ដែលដើមបណ្តឹងរដ្ឋប្បវេណីរស់នៅ។ ជាពិសេស ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើតុលាការមេត្តាផ្តល់សំណងមួយចំនួនដែលអាចស្ថិតនៅក្រោមផ្នែកកម្មវិធីផ្សព្វផ្សាយ និងការផ្សព្វផ្សាយព័ត៌មាន ដូចជាការសូមអភ័យទោស តំហែទាំវេជ្ជសាស្ត្រ រួមមានការថែទាំផ្លូវកាយ និងផ្លូវចិត្ត កម្មវិធីសិក្សាអប់រំ និងការរម្លឹកដល់ជនរងគ្រោះ។ អនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់អំពីទម្រង់នៃសំណងដែលស្នើសុំ[13] និងមានបំណងទាមទារដោយជាក់លាក់នូវសំណងផ្លូវចិត្ត និងសមូហភាព នៅក្នុងសេចក្តីសន្និដ្ឋានស្ថាពរ[14]។

### *ក. កម្មវិធីផ្សព្វផ្សាយ ការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយព័ត៌មាន*

១២. ជាចំណែកមួយនៃដំណើរការព្យាបាលជាសមូហភាព ការគាស់កកាយការពិតអំពីហេតុការណ៍អតីតកាល និងអំពីអ្នកដែលទទួលខុសត្រូវ គឺជាគោលដៅសំខាន់នៃការសងសំណងដល់ជនរងគ្រោះ និងគ្រួសាររបស់ពួកគាត់។ ហេតុដូច្នេះ វាជាការចាំបាច់ដែលការផ្តល់សំណងក្នុងកម្រិតអប្បបរិមា ត្រូវរួមបញ្ចូលទាំងការចែកចាយលទ្ធផលនៃការជំនុំជម្រះ តាមរយៈកម្មវិធីផ្សព្វផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ក្នុងនោះរួមមានសារព័ត៌មាន ទស្សនាវដ្តី ទូរទស្សន៍ និងវិទ្យុ ដែលអនុញ្ញាតឱ្យជនរងគ្រោះមានអារម្មណ៍ថា ខ្លួនត្រូវបានគេរាប់បញ្ចូល

---

[13] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ១។

[14] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, កថាខណ្ឌ៥។

និងបានចូលរួមក្នុងដំណើរការយុត្តិធម៌។ កម្មវិធីផ្សព្វផ្សាយដល់មូលដ្ឋានប្រកបដោយប្រសិទ្ធភាពមានភាពចាំបាច់សម្រាប់កំណត់ការសង្ឃឹមទុករបស់ជនរងគ្រោះ និងក៏ដូចជាសហគមន៍របស់ពួកគាត់ និងដើម្បីផ្តល់ទំនុកចិត្តឱ្យកាន់តែខ្លាំងទៅឱ្យជនរងគ្រោះ ដែលពួកគាត់អាចកំពុងជួបការលំបាក ក្នុងការនិយាយរៀបរាប់រឿងរ៉ាវរបស់ពួកគាត់។ ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន៥ភាគរយ ដែលបានលើកឡើងយ៉ាងច្បាស់លាស់អំពីទម្រង់នៃសំណងក្នុងទម្រង់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់នោះ បានស្នើសុំសំណងទាក់ទិននឹងការបោះពុម្ពផ្សាយឯកសារដែលពាក់ព័ន្ធនឹងខ្មែរក្រហម និងជាពិសេសពាក់ព័ន្ធនឹងសំណុំរឿងនេះ[15]។

១៣. ច្បាស់ណាស់ អ.វ.ត.ក គឺជាអ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការព្យាបាល និងការពិតដែលកាន់តែទូលំទូលាយ តាមរយៈការផ្តល់ឱកាសឱ្យជនរងគ្រោះ និងចារី និយាយប្រាប់រឿងរ៉ាវរបស់ពួកគាត់ក្នុងវង្វង់នៃសំណុំរឿងមួយ និងលាតត្រដាងព័ត៌មានសំខាន់ៗពីឯកសារប្រវត្តិសាស្ត្រដែលអាចឱ្យសញ្ញាណនៃ"ការពិត"លេចចេញជារូបរាង។ តាមការពិត តុលាការគឺជាអ្នកទទួលខុសត្រូវ តាមរយៈផ្នែកកិច្ចការសាធារណៈរបស់ខ្លួន ចំពោះការរៀបចំចាត់ចែងកិច្ចការរៀបចំកម្មវិធីផ្សព្វផ្សាយដល់មូលដ្ឋាន។

១៤. បើទោះបីជាយ៉ាងដូច្នេះក្តី កិច្ចខិតខំប្រឹងប្រែងឱ្យបានខ្លាំងក្លាជាងនេះ គឺមានភាពចាំបាច់ក្នុងបញ្ហានេះ។ គេបានកត់សម្គាល់ឃើញថា តុលាការនេះអាចចេញដីកាដោយភ្ជាប់ជាមួយកាតព្វកិច្ច ទៅកាន់ការិយាល័យរដ្ឋបាល និងការិយាល័យកម្មវិធីផ្សព្វផ្សាយ អំពីអ្វីដែលត្រូវធ្វើឱ្យបានជាក់លាក់។ ក្នុងការសិក្សាពិសោធន៍មួយនាពេលថ្មីៗ ស្តីពីអាកប្បកិរិយារបស់ជនជាតិកម្ពុជាចំពោះការកសាងសង្គមឡើងវិញ ដែលទំនងជាការស្ទាបស្ទង់ធំជាងគេបង្អស់មួយមកទល់នឹងពេលបច្ចុប្បន្ន ដែលក្នុងនោះមានអ្នកឆ្លើយសំណួរចំនួន១.០០០នាក់ ក្នុងនោះ៣៩ភាគរយឆ្លើយថាពួកគេ "ពុំបានដឹង" អំពី អ.វ.ត.ក ឡើយ។ ៤៦ភាគរយ "បានដឹងតិចតួច"ប៉ុណ្ណោះ ហើយ១៥ភាគរយទៀត ឆ្លើយថាបាន "ដឹងខ្លះៗ"។ អំឡុងពេល ១ខែមុនពេលធ្វើការស្ទាបស្ទង់ ៦៤ភាគរយនៃអ្នកឆ្លើយសំណួរ ត្រូវបានគេរាយការណ៍ថាពុំបានដឹងឮអ្វីទាល់តែសោះអំពី អ.វ.ត.ក ក្នុងប្រព័ន្ធផ្សព្វផ្សាយ ឬប្រភពព័ត៌មានផ្សេងៗ។

[15] អ.វ.ត.ក, របាយការណ៍ស្ថិតិអង្គភាពជនរងគ្រោះ, ភ្ជាប់ជាមួយឯកសារនេះជាឧបសម្ព័ន្ធ១។

E159/3



ក្នុងពេលធ្វើការស្ទាបស្ទង់ នៅពេលសួរអំពីចំនួនអ្នកដែលគេបានចាប់ខ្លួន និងកំពុងរង់ចាំការជំនុំជម្រះ ឃើញថាមានតែ១០ភាគរយប៉ុណ្ណោះ ដែលមានលទ្ធភាពឆ្លើយត្រូវ។ មានតែ៣ភាគរយប៉ុណ្ណោះ ដែលមានលទ្ធភាពប្រាប់ឈ្មោះជនជាប់ចោទទាំងប្រាំនាក់បាន។ ក្នុងចំណោមអ្នកដែលបានដឹងអំពី អ.វ.ត.ក យើងឃើញថាទូរទស្សន៍ និងវិទ្យុ ហាក់បីដូចជាប្រភពព័ត៌មាន ដែលពួកគាត់ជឿទុកចិត្តជាងសារព័ត៌មាន[16]។

១៥. បើទោះបីជាស្ថិតិខាងលើស្ថិតក្នុងចុងឆ្នាំ២០០៨ ហើយវាឆ្លុះបញ្ចាំងឱ្យឃើញទស្សនៈរបស់ប្រជាជនកម្ពុជាទូទៅទាំងអស់ ជាជាងទស្សនៈដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះក្ដី ក៏ស្ថិតិទាំងនេះនៅតែបង្ហាញឱ្យយើងដឹងថា គេត្រូវតែធ្វើកិច្ចការជាច្រើនថែមទៀត ក្នុងក្របខណ្ឌកម្មវិធីផ្សព្វផ្សាយ។ បើទោះបីយ៉ាងដូច្នេះក្ដី ក៏សកម្មភាពកម្មវិធីផ្សព្វផ្សាយទូទៅ រួមទាំងអំពីលទ្ធផលនៃការជំនុំជម្រះផង គួរត្រូវបានផ្សព្វផ្សាយដោយផ្នែកកិច្ចការសាធារណៈរបស់តុលាការ និងពុំគួរត្រូវចាត់ទុកថាជា "ការផ្ដល់" សំណងមួយទៅឱ្យជនរងគ្រោះឡើយ។ ជនរងគ្រោះពុំអាចត្រូវបានគេ "ផ្ដល់" ឱ្យនូវអ្វីមួយដែលតុលាការមានកាតព្វកិច្ចត្រូវបំពេញរួចទៅហើយនោះទេ។

១៦. យ៉ាងណាក្ដី សកម្មភាពកម្មវិធីផ្សព្វផ្សាយបន្ថែមមួយចំនួនទៀត អាចត្រូវបានចាត់ទុកថាជា "ការផ្ដល់"សំណងដោយតុលាការ ដោយហេតុថាសកម្មភាពទាំងនោះប្រហែលនឹងពុំស្ថិតក្រោមសកម្មភាពកម្មវិធីផ្សព្វផ្សាយ ទូទៅរបស់ផ្នែកកិច្ចការសាធារណៈឡើយ។ ឧទាហរណ៍ដូចជាការតម្រូវឱ្យធ្វើការចងក្រងពាក្យសូមអភ័យទោស របស់ឌុចដែលគាត់បាននិយាយក្នុងគ្រប់ដំណាក់កាលនៃការជំនុំជម្រះ។ បន្ទាប់មកពាក្យសម្ដីថ្លែងសូមអភ័យទោសទាំងនេះ អាចត្រូវបានយកទៅផ្សព្វផ្សាយគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា តាមរយៈអង្គភាពជនរងគ្រោះ ដោយបញ្ចូលជាមួយនឹងទស្សនៈយល់ឃើញជាសាធារណៈ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានលើកឡើងក្នុងចម្លើយរបស់ពួកគេ នៅចំពោះមុខតុលាការ និង/ឬ ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ។ ឧទាហរណ៍មួយទៀត ដូចជាការសម្រួលឱ្យមានការសូមអភ័យទោសពីសំណាក់ឌុច ឈរលើការយល់ឃើញថាគាត់នឹងសហការ និងគោរពជនរងគ្រោះ។ ក្នុងន័យនេះ ការគោរពមានន័យថា ឌុច ពុំគួរសូមអភ័យទោស រួចបន្ទាប់មកបែរជាអះអាង

[16] Phuong Pham និងអ្នកផ្សេងទៀត, *So We Will Never Forget, យោងខាងលើ* កំណត់សម្គាល់៥, ទំព័រ៣៨។

ថាគាត់គ្រាន់តែធ្វើតាមបញ្ជាថ្នាក់លើនោះទេ។ ការសូមអភ័យទោសដែលឈរលើការដោះសារយករួចខ្លួនបែបនេះ វាបានត្រឹមតែធ្វើឱ្យជនរងគ្រោះឈឺចាប់ប៉ុណ្ណោះ ហើយធ្វើឱ្យការសូមអភ័យទោសរបស់ឌុចហាក់ដូចគ្មានភាពស្មោះត្រង់បន្តិចណាឡើយ។

## *ខ. ការផ្តល់ការថែទាំវេជ្ជសាស្ត្រ*

១៧. ទាក់ទិននឹងទម្រង់នៃសំណង យោងតាមព័ត៌មានដែលអង្គភាពជនរងគ្រោះផ្តល់ឱ្យ ឃើញថា២១ភាគរយនៃដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំសំណងនោះ ពួកគាត់ចង់បានសេវាទាក់ទងនឹងវេជ្ជសាស្ត្រ។ ទម្រង់នៃសំណងនេះមានភាពចាំបាច់ជាពិសេស ដោយសារតែអាយុរបស់ជនរងគ្រោះកើនឡើង[17]។ តួលេខនេះស្របជាមួយនឹងលទ្ធផលបានមកពីការសិក្សាពិសោធន៍ដែលបាននិយាយពីខាងដើមដែលបានបង្ហាញថា ២០ភាគរយនៃអ្នកឆ្លើយសំណួរបានឆ្លើយថាជនរងគ្រោះគួរត្រូវបានគេផ្តល់ឱ្យនូវសេវាសង្គម មានដូចជាសេវាសុខភាព ការសិក្សាអប់រំ និងការពិគ្រោះយោបល់ផ្លូវចិត្តជាដើម[18]។

*<u>ការថែទាំផ្លូវចិត្ត</u>*

១៨. ការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំ ពាក់ព័ន្ធទៅនឹងការបង្កឱ្យមានព្យសនកម្មផ្លូវចិត្តយ៉ាងធំធេងដល់ជនរងគ្រោះ និងគ្រួសាររបស់ពួកគាត់ដែលអាចមានរយៈពេលមួយជីវិត។ ការផ្តល់ការព្យាបាលផ្លូវចិត្ត និងការជួយឧបត្ថម្ភគាំទ្រអាចដើរតួនាទីយ៉ាងរឹងមាំក្នុងការស្តារនីតិសម្បទាតាមរយៈការជួយជនរងគ្រោះ និងគ្រួសាររបស់ពួកគាត់ឱ្យប្រឈមមុខ និងដោះស្រាយការប៉ះទង្គិចផ្លូវចិត្ត និងការរំលោភបំពាន។ ទោះបីជាការជួយឧបត្ថម្ភគាំទ្របែបនេះ(ឬវិធានការសងសំណងផ្សេងៗ) វាមិនទំនងជាអាចស្តារជនរងគ្រោះឱ្យស្ថិតក្នុងសភាពដូចមុនពេលមានរបួសស្នាមនោះក៏ដោយ ការជួយឧបត្ថម្ភគាំទ្រអាចជួយព្យាបាលបានខ្លះៗនូវព្យសនកម្មផ្លូវចិត្ត ការឈឺចាប់ ទុក្ខវេទនា និងការឈឺចាប់ផ្លូវចិត្ត ដែលពួកគាត់កំពុងទទួលរង។

---

[17] អ.វ.ត.ក, របាយការណ៍ស្ថិតិអង្គភាពជនរងគ្រោះ, ភ្ជាប់ជាមួយឯកសារនេះជាឧបសម្ព័ន្ធ១។

[18] *ដូចជើងទំព័រខាងលើ*, ត្រង់ទំព័រ៤៥។

១៩. ជាក់ស្តែង កម្មវិធីសំណង និងការថែទាំសុខភាពទូលំទូលាយសម្រាប់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស (PRAIS) បានផ្តល់ឱ្យជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស នៅក្នុងប្រទេសឈីលី (ព្រមទាំង គ្រួសាររបស់ពួកគាត់) នូវការពិគ្រោះយោបល់ដោយឥតយកប្រាក់ និងការជួយឧបត្ថម្ភគាំទ្រ ដល់បញ្ហាផ្លូវចិត្ត និងស្មារតីផ្សេងៗ។ សេវាជំនួយនេះពុំត្រឹមតែបានផ្តល់ការព្យាបាលជំងឺធ្លាក់ទឹកចិត្ត ជំងឺថប់អារម្មណ៍ និងការឈឺចាប់ផ្លូវចិត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានទាក់ទាញការយកចិត្តទុកដាក់ ទៅដល់ផលប៉ះពាល់ខូចខាតអំពីការរំលោភសិទ្ធិមនុស្សទៀតផង[19]។

២០. នៅឯ អ.វ.ត.ក អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) បច្ចុប្បន្នបាននឹងកំពុងផ្តល់ជំនួយគាំទ្រ ផ្នែកផ្លូវចិត្តទៅដល់សាក្សីជាច្រើននាក់ និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១។ កិច្ចខិតខំទាំងអម្បាលម៉ានរបស់ពួកគាត់ក្នុងការផ្តល់ការពិគ្រោះយោបល់ដោយឥតគិតប្រាក់គួរត្រូវបានជួយគាំទ្រ និងពង្រឹងតាមរយៈការផ្តល់សំណង ដោយហេតុថាបច្ចុប្បន្នពួកគាត់មានលទ្ធភាពផ្តល់ជំនួយគាំទ្រភ្លាមៗ។

*<u>ការថែទាំផ្លូវកាយ</u>*

២១. ការធ្វើទារុណកម្ម ការធ្វើការងារពលកម្មដោយបង្ខំ ការកង្វះអាហារូបត្ថម្ភ និងលក្ខខណ្ឌមិនល្អនៃការឃុំឃាំងកាលពីពេលអតីតកាល អាចប៉ះពាល់យ៉ាងខ្លាំងទៅដល់សុខភាពជនរងគ្រោះ។ លើសពីនេះ ការប៉ះទង្គិចផ្លូវចិត្តក៏អាចបង្កឱ្យមានព្យសនកម្មផ្លូវកាយផងដែរ។ ព្យសនកម្មផ្លូវកាយអស់ទាំងនេះមានសភាពកាន់តែធ្ងន់ធ្ងរទៅ ដូចជាការកើនឡើងនៃអាយុរបស់ជនរងគ្រោះដែរ។ ដោយមូលហេតុទាំងអស់នេះ តុលាការគួរពិចារណាអំពីសុខភាពផ្លូវកាយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពចាំបាច់សម្រាប់ការថែទាំសុខភាពពួកគាត់។

---

[19] Elizabeth Lira "គោលនយោបាយសំណងសម្រាប់ការរំលោភសិទ្ធិមនុស្សនៅប្រទេស Chile (The Reparation for Human Rights Violations in Chile)" *នៅក្នុង* Pablo De Greiff, ប្រែសម្រួល *កូនសៀវភៅនៃសំណង (The Handbook of Reparations)* មជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌តាមទម្លាប់ (International Center for Traditional Justice) (២00៦) ទំព័រ៦៧។

ហេតុនេះ គេគួរតែផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី នូវការថែទាំសុខភាពដោយឥតបង់ប្រាក់ រួមទាំងការធ្វើដំណើរទៅកាន់មណ្ឌលសុខភាពផង។

២២. ការជួយឧបត្ថម្ភគាំទ្រដល់បញ្ហាផ្នែកផ្លូវកាយ និងផ្លូវចិត្តនេះគឺជាការចាំបាច់សម្រាប់ការជាសះស្បើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះ។ ជាពិសេសសម្រាប់អ្នកដែលបានទទួលរងព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរ ការពិគ្រោះយោបល់ និងការថែទាំវេជ្ជសាស្ត្រទូទៅមានសារសំខាន់ដល់ដំណើរការព្យាបាល[20]។

## *គ. កម្មវិធីសិក្សាអប់រំ*

២៣. បន្ថែមពីលើការផ្សព្វផ្សាយអប់រំនិងការថែទាំសុខភាព មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យការសម្រេចជួសជុលសំណងមានរួមបញ្ចូលទាំងសមាសភាគសិក្សាអប់រំមួយទៀតផង។ យោងតាមព័ត៌មានដែលផ្តល់ដោយអង្គភាពជនរងគ្រោះ ១២ភាគរយនៃដើមបណ្តឹងរដ្ឋប្បវេណីដែលបានរៀបរាប់ទម្រង់នៃសំណងយ៉ាងជាក់លាក់នោះ បានស្នើសុំវិធានការសិក្សាអប់រំ[21]។

២៤. វិធានការមួយដែលអាចធ្វើបាន អាចរួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងផ្នែកអប់រំដែលបានកើនឡើងពាក់ព័ន្ធនឹងការសិក្សាលើការរំលោភបំពានសិទ្ធិមនុស្សដ៏ច្រើន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ឯកសារអំពី "ការពិត" ជាប្រវត្តិសាស្ត្រនៅពីក្រោយរបបខ្មែរក្រហម ត្រូវបានដាក់បញ្ចូលទៅក្នុងសៀវភៅសិក្សា ដូចនេះវាជាការលើកតម្កើងដល់គោលបំណងផ្នែកសិក្សាអប់រំផងដែរ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានតួនាទីសំខាន់ចំពោះបញ្ហានេះណាស់ ពីព្រោះពួកគាត់បានចាប់ផ្តើមដំណើរការគម្រោងសំខាន់ៗមួយចំនួនរួចទៅហើយដែលតុលាការអាចគាំទ្របាន តាមរយៈការសម្រេចផ្តល់

---

[20] គណៈកម្មការការពិតនិងការផ្សះផ្សា (Truth and Reconciliation Commissions) បានជួយផ្តល់និយមន័យនៃអ្នកទទួលការថែទាំផ្នែកចិត្តសាស្ត្រក្នុងប្រទេស Chile និងបានសង្កត់ធ្ងន់ទៅលើតម្រូវការចំពោះការផ្តល់ប្រឹក្សាសម្រាប់ជនរងគ្រោះនៃអំពើទុរណកម្ម អតីតជនត្រូវនិរទេស និងក្រុមគ្រួសាររបស់អ្នកដែលត្រូវបានសម្លាប់។ *ដូចដើងទំព័រខាងលើ*, ទំព័រ៥៦, ៦៩។

[21] អ.វ.ត.ក, របាយការណ៍ស្ថិតិអង្គភាពជនរងគ្រោះ, ភ្ជាប់ជាមួយឯកសារនេះជាឧបសម្ព័ន្ធ១។

E159/3



សំណងបន្ថែមទៀត។ សំណងនានាអាចសំដៅទៅលើប្រាក់បៀវត្សរ៍ និងការបណ្តុះបណ្តាលគ្រូបង្រៀន ការផ្តល់អគារ/បរិក្ខាសិក្សានានា ការរៀបចំកម្មវិធីសិក្សា ការផ្សព្វផ្សាយ សម្ភារៈសិក្សា និងការបន្តការបណ្តុះបណ្តាលដល់អ្នកចូលរួមតាមមូលដ្ឋាននៅក្នុងកម្មវិធីសិក្សាអប់រំអំពីសិទ្ធិនានា[22]។

២៥. ជម្រើសម្យ៉ាងទៀតគឺការគាំទ្រកម្មវិធីសិក្សាអប់រំ "ដឹងពីសិទ្ធិរបស់អ្នក" ដែលអាចមានប្រសិទ្ធភាពនៅក្នុងការងើបឡើងវិញនៃស្មារតី និងការយល់ដឹងពីសិទ្ធិមនុស្សរបស់សង្គមកម្ពុជាព្រមទាំងដើរតួនាទីជាវិជ្ជមាននៅក្នុងការស្ថាបនា និងការការពារសិទ្ធិតាមផ្លូវច្បាប់។ លើសពីនេះទៀត ការបណ្តុះបណ្តាលសិទ្ធិស៊ីវិលនិងសិទ្ធិមនុស្សអាចប្រព្រឹត្តទៅនៅក្នុងសហគមន៍មូលដ្ឋាន ដើម្បីអប់រំប្រជាជនកម្ពុជាអំពីសិទ្ធិនានារបស់ពួកគាត់។ ឧទាហរណ៍ ការិយាល័យផ្សព្វផ្សាយអប់រំ និងកិច្ចការសាធារណៈសម្រាប់តុលាការពិសេសសម្រាប់សេរ៉ាឡេអូន (SCSL) បានផ្តល់ការអប់រំដល់កុមារផង ដល់មនុស្សពេញវ័យផង។ ការផ្សព្វផ្សាយអប់រំត្រូវបានផ្តល់ដល់ប្រជាជនតាមមូលដ្ឋាន តាមរយៈការពង្រឹងសមត្ថភាពផ្នែកនីតិរដ្ឋដល់រដ្ឋាភិបាល និងដល់មន្ត្រីតុលាការនានានៅគ្រប់ជាន់ថ្នាក់។ កម្មវិធីយេនឌ័រផ្តល់នូវការយល់ដឹងអំពីស្ថានភាពរបស់ស្ត្រីនៅក្នុងប្រទេស ចំណែកឯ "កុមារនិយាយទៅកាន់កុមារ" គឺជាកម្មវិធីវិទ្យុមួយប្រភេទដែលផ្តល់ដល់ កុមារនូវនាទីមួយដែលមានប្រធានបទជជែកពិភាក្សាគ្នានិងមានការចោទសួរគ្នា[23]។ ជាមួយនឹងការផ្តល់មូលនិធិសមរម្យ និងគោលបំណងដែលមានកំណត់ មានឧទាហរណ៍ជាច្រើនដែលបង្ហាញថា ការសម្រេចផ្តល់សំណងផ្នែកអប់រំ អាចបន្សល់ទុកនូវផលប៉ះពាល់ជាវិជ្ជមានជាប់ជារៀងរហូតដល់សង្គមកម្ពុជាទាំងមូល។

---

[22] Jaya Ramji, *យោងខាងលើ* កំណត់សម្គាល់៣, ទំព័រ ៣៧០។

[23] តុលាការពិសេសសម្រាប់ប្រទេស Sierra Leone, "ការផ្សព្វផ្សាយនិងកិច្ចការសាធារណៈ" *អាចមើលបាននៅ* http://www.sc-sl.org/ABOUT/CourtOrganization/TheRegistry/OutreachandPublicAffairs/tabid/83/Default.aspx.

23 តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា, "សមិទ្ធផលរបស់តុលាការ ICTR" *អាចមើលបាននៅ* http://69.94.11.53/ENGLISH/factsheets/achievements.html ។ ក្នុងប្រទេសកម្ពុជា អង្គការបារាំងមួយឈ្មោះថា "មេធាវីគ្មានព្រំដែន" បានរៀបចំកម្មវិធីយល់ដឹងផ្នែកច្បាប់មួយ នៅក្នុងមណ្ឌលថែរក្សាក្មេងកំព្រា នៅតាមបណ្តាខេត្តជាច្រើន។ នៅក្នុងប្រទេសបារាំង កម្មវិធីយល់ដឹងអំពីសិទ្ធិមនុស្សត្រូវបានបង្កើតឡើងដោយ "L'ecole des droits de L'homme"។ http://www.ecoledesdroitsdelhomme.org/ ។

## *ឃ. ពិធីរម្លឹក*

២៦. ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន បានស្នើសុំឱ្យការសម្រេចផ្ដល់សំណងមានរួមបញ្ចូល នូវការបង្កើតវត្តសហគមន៍ របងវត្ត ឬបូជនីយដ្ឋានរម្លឹកដល់អ្នកជាទីស្រលាញ់របស់ពួកគាត់។ របាយការណ៍របស់អង្គភាពជនរងគ្រោះ បង្ហាញថា ១៤ភាគរយ នៃដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានស្នើសុំទម្រង់បែបបទនៃសំណងយ៉ាងច្បាស់លាស់នោះ បានស្នើសុំអគារសាសនា បួនភាគរយបានស្នើសុំពិធីបញ្ចុះសពឡើងវិញ និងប្រាំពីរភាគរយទៀតបានស្នើសុំអគារបូជនីយដ្ឋានមួយ[24]។ ទោះបីជាពួកគាត់ទទួលស្គាល់ថា បូជនីយដ្ឋានរម្លឹកដល់ជនរងគ្រោះនៃរបបខ្មែរក្រហមមួយចំនួនត្រូវបានកសាង រួចរាល់ហើយក៏ដោយ[25] ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានស្នើសុំធ្វើការរំលឹកវិញ្ញាណក្ខន្ធជាពិសេស ដល់សាច់ញាតិរបស់ខ្លួនដែលជាជនរងគ្រោះនៃមន្ទីរ ស-២១។

២៧. បូជនីយដ្ឋានជនរងគ្រោះនៃមន្ទីរ ស-២១ អាចក្លាយជាផ្នែកមួយនៃដំណើរការកាន់ទុក្ខនិងការសម្រួលសតិអារម្មណ៍។ វត្ត ឬក៏បូជនីយដ្ឋាននានា ដូចជាវិមាន វិហារ ឬសារមន្ទីរ តំណាងឱ្យប្រវត្តិសាស្ត្ររបស់ប្រជាជន និងលទ្ធភាពសម្រាប់សហគមន៍ ធ្វើបន្តទៀតព្រោះកន្លែងទាំងនោះ "តំណាងឱ្យការចងចាំ"[26]។ ទោះបីជាយ៉ាងណាក្ដី ក្នុងពេលបង្កើតកន្លែងរម្លឹកការចងចាំ ឬគោរពបូជាដល់ជនរងគ្រោះពីការ រំលោភសិទ្ធិមនុស្ស និងជនរងគ្រោះនៃមន្ទីរ ស-២១ វាមានសារៈសំខាន់ណាស់ក្នុងការពិចារណាដល់វប្បធម៌និងទំនៀមទម្លាប់តាមមូលដ្ឋាន។

---

[24] អ.វ.ត.ក, របាយការណ៍ស្ថិតិអង្គភាពជនរងគ្រោះ, ភ្ជាប់ជាមួយឯកសារនេះជាឧបសម្ព័ន១។

[25] Rachel Hughes, "ការប្រព្រឹត្តអំពើប្រល័យពូជសាស្ត្រ៖ កម្ពុជាមុនឆ្នាំ១៩៧៩ និងភូមិសាស្ត្រនយោបាយនៃការចងចាំ", ថ្នាក់បណ្ឌិត, សាកលវិទ្យាល័យ Melbourne (២០០៦)។ បណ្ឌិត ហេឡិន ចារវីស "ការគូរផែនទី 'វាលពិឃាតដកម្ពុជា'" *នៅក្នុង* Jonh Schofiel, William Gray Johnson និង Colleen M. Beck, ប្រែសម្រួល, *Matériel culture: the archaeology of 20th century conflict*, បោះពុម្ពនៅ London & New York (២០០២)។

[26] Bradon Hamber, "Narrowing the Micro and Macro: A Psychological Perspective on Reparations in Societies in Transition," *នៅក្នុង* Pablo De Greiff, ប្រែសម្រួល, *កម្រងឯកសារសំណង*, មជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌តាមទម្លាប់ (២០០៦), ទំព័រ ៥៦៧។

២៨. មានសំណើជាក់លាក់ជាច្រើនដើម្បីកសាងបូជនីយដ្ឋាននៅទីតាំងមន្ទីរ ស-២១ នៅបឹងជើងឯក និងនៅគុកព្រៃស។ សំណើរួមបញ្ចូលនូវស្លាកសញ្ញារម្លឹកដែលរាយឈ្មោះ ជនរងគ្រោះដែលគេស្គាល់ទាំងអស់ ក្ដារខៀនផ្ដល់ព័ត៌មានដែលមានរាយឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី និងនិយាយពីរឿងរ៉ាវរបស់ពួកគាត់ប្រាប់ដល់សាធារណជនព្រមទាំងរូបសំណាកដែលជានិមិត្តរូបឱ្យការឈឺចាប់របស់ជនរងគ្រោះនានា។

២៩. បន្ថែមពីលើបូជនីយដ្ឋាន ឬរូបសំណាកនៅមន្ទីរ ស-២១នោះ ដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើជាពិសេសសុំឱ្យកសាងវត្ត ឬរបងវត្ត ដើម្បីផ្ដល់កិត្តិយសដល់អ្នកជាទីស្រលាញ់ របស់ពួកគាត់[27]។ វត្តនានានៅក្នុងប្រទេសកម្ពុជា ជាញឹកញាប់ស្ថិតនៅចំកណ្ដាលភូមិ និងអាចប្រើប្រាស់សម្រាប់ការសិក្សាអប់រំ សម្រាប់ការគោរពបូជាដោយព្រះសង្ឃ ឬសម្រាប់ជាបូជនីយដ្ឋាន។ សម្រាប់ជនរងគ្រោះជាច្រើននាក់ដែលមានតែវត្តតូចមួយ ឬរបងវត្តនោះនឹងអនុញ្ញាតឱ្យពួកគាត់មានកន្លែងតាំងសមាធិ ដើម្បីរម្លឹកដល់អ្នកដែលខ្លួនស្រលាញ់។ ជាការពិត ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើននាក់នៅក្នុងសំណុំរឿងលេខ ០០១ មិនបានរស់នៅក្បែរទីក្រុងភ្នំពេញនោះទេ ហើយការមានវត្តតូចមួយ ឬរបងវត្តនៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួនបន្ថែមពីលើបូជនីយដ្ឋានដែលបង្កើតឡើងនៅមន្ទីរ ស-២១នោះ នឹងបម្រើផលប្រយោជន៍របស់ពួកគាត់បានកាន់តែប្រសើរឡើង។

៣០. ទម្រង់បែបបទនៃពិធីរម្លឹកផ្សេងទៀតដែលបានស្នើសុំ រួមមានៈ ការសរសេរឈ្មោះ ជនរងគ្រោះនៅក្នុងចេតិយ ឬនៅលើស្លាករម្លឹកដើម្បីដាក់នៅមន្ទីរ ស-២១ ដោយបានផ្សព្វផ្សាយឈ្មោះជនរងគ្រោះនានាជូនដល់ស្ថាប័នសិក្សាអប់រំទាំងអស់ សារមន្ទីរទេសចរណ៍ ដែលជាកន្លែងរូបថតនិងរឿងរ៉ាវរបស់ជនរងគ្រោះ អាចត្រូវបានចែករំលែកជូនដល់ប្រជាជនកម្ពុជាដែលមិនអាចមកមើលនៅភ្នំពេញបាន ការកសាងរូបសំណាក រម្លឹកវិញ្ញាណក្ខន្ធនៅមន្ទីរ

---

[27] មានវត្តជាច្រើននៅទូទាំងប្រទេសកម្ពុជា ដែលផ្ដល់ជាកន្លែងចងចាំចំពោះអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។ ឧទាហរណ៍ វត្តក្ដីដូង ស្ថិតនៅចំកណ្ដាលវណ្ដៅសាកសពរួម ដែលមនុស្សជាច្រើនត្រូវបានកប់នៅរវាងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដោយរបបខ្មែរក្រហម។ ធាតុរបស់ជនរងគ្រោះស្ថិតនៅក្នុងបរិវេណវត្ត និងក្នុងចេតិយសម្រាប់ជាកន្លែងរំលឹក សូមមើលគេហទំព័រ ការកាត់ទោសមេដឹកនាំខ្មែរក្រហម "វត្តក្ដីដូងពិសិដ្ឋ ជាអតីតវាលពិឃាដ" *អាចមើលបាននៅ* http://www.krtrial.info/showarticle.php?language=english&action=showarticle&art_id=2918needback=1 ។

ស-២១ នៅបឹងជើងឯក និងនៅគុកព្រៃស ការដាក់បញ្ចូលឈ្មោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជាផ្នែកនៃការតាំងបង្ហាញដែលមានស្រាប់នៅមន្ទីរ ស-២១ ព្រមទាំងការដាក់ឈ្មោះស្ថាប័នសំខាន់ៗ ដូចជាមន្ទីរពេទ្យ តាមឈ្មោះជនរងគ្រោះនៃមន្ទីរ ស-២១ ដ៏ច្រើនរាប់មិនអស់។ ហេតុនេះ ដោយបានពិចារណាដល់ការជាប់ទាក់ទងនឹងវប្បធម៌ វាមានសារៈសំខាន់ណាស់ទាំងចំពោះការផ្ដល់កិត្តិយស ទាំងការរម្លឹកដល់ជនរងគ្រោះនៃមន្ទីរ ស-២១ តាមរយៈការកសាងទីកន្លែងធ្វើពិធីរម្លឹកនានា។

## V. ការផ្ដល់ប្រាក់សំណង នៅក្នុងករណីជនជាប់ចោទមានភាពទុរគត

៣១. បញ្ហាប្រឈមដ៏ធំបងជាងគេបំផុតដែលនៅចំពោះមុខតុលាការនេះ គឺការសម្រេចថា ត្រូវផ្ដល់សំណងដ៏សំខាន់ និងដ៏មានន័យនានាបានដោយរបៀបណា នៅពេលដែលជនជាប់ចោទត្រូវបានកំណត់មើលឃើញថាពិតជាមានភាពទុរគតនោះ។ វិធាន ២៣(១១) នៃវិធានផ្ទៃក្នុង ដែលបានចែងថា ការផ្ដល់សំណងត្រូវតែអនុវត្តដោយ ជនជាប់ចោទដែលបានទទួលការកាត់ទោសនោះ អាចត្រូវបានបកស្រាយតាមវិធីពីរ យ៉ាង។ ទីមួយ គេអាចបកស្រាយថា ការផ្ដល់សំណងអាចបង់បានដោយជនជាប់ចោទ *តែប៉ុណ្ណោះ* ដោយមិនគិតអំពីថាតើជនល្មើសនោះមានភាពទុរគត ឬយ៉ាងណានោះទេ។ ការបកស្រាយបែបនេះមានន័យថា ប្រសិនបើជនល្មើសត្រូវគេយល់ឃើញថាមានភាពទុរគត នៅពេលនោះពុំមានប្រភពផ្ដល់ប្រាក់ផ្សេងទៀតមិនថាតែបង្កើតដោយព្រះរាជាណាចក្រកម្ពុជា ឬតាមរយៈមូលនិធិស្ម័គ្រចិត្តណាមួយ អាចអនុវត្តសម្រាប់ការផ្ដល់សំណងនេះបានទេ។

៣២. ប្រសិនបើការបកស្រាយនេះត្រូវបានអនុម័តដោយតុលាការនោះ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថា ការសន្យាផ្ដល់ភាពយុត្តិធម៌តាមរយៈប្រាក់សំណង ដល់ជនរងគ្រោះនៃមន្ទីរ ស-២១ នោះ នឹងមិនមានន័យអ្វីឡើយ។ លើសពីនេះទៀត សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើដោយគោរពសុំឱ្យមានការផ្ដល់ភស្តុតាងដល់ភាគីនានា ដោយគូសបញ្ជាក់ពីស្ថានភាពទុរគតរបស់ជនល្មើសផង។ ទ្រង់ទ្រាយសំខាន់នៃការកែលម្អ ដំណើរការនៃកិច្ចខិតខំប្រឹងប្រែងរកប្រាក់សំណងស្រប តាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញបច្ចុប្បន្ននេះ គឺដើម្បីធានាថាតុលាការ និងគ្រប់ភាគីទាំងអស់

E159/3



ដែលពាក់ព័ន្ធបានទទួលនូវព័ត៌មានគ្រប់គ្រាន់ស្តីពីស្ថានភាពហិរញ្ញវត្ថុ របស់ជនជាប់ចោទ ដូចជាព័ត៌មានស្តីពីទ្រព្យសម្បត្តិរបស់ជនជាប់ចោទ និងយុទ្ធសាស្ត្រ សមទំនងរបស់ពួកគេពាក់ព័ន្ធនឹងការលាក់បាំង ឬការផ្លាស់ប្តូរទីកន្លែងទុកទ្រព្យសម្បត្តិ ដែលអាចកើតមានឡើង។ នៅក្នុងរឿងក្តីនេះ វាបង្ហាញឱ្យឃើញថា ពុំមានភស្តុតាង ច្បាស់លាស់នៃការវាយតម្លៃអំពីទ្រព្យសម្បត្តិពិតប្រាកដរបស់ជនជាប់ចោទ នៅក្នុងសំណុំរឿងនោះឡើយ ទោះបីជាមានការទទួលស្គាល់ថា គាត់បានជាប់នៅក្នុងមន្ទីរឃុំឃាំង អស់រយៈពេលជាង១០ឆ្នាំទៅហើយក៏ដោយ។ ហេតុដូច្នេះហើយ មានសេចក្តីត្រូវការបន្ទាន់មួយឱ្យមានការទទួលខុសត្រូវ និងតម្លាភាពខ្លាំងក្លាជាងនេះនៅក្នុងដំណើរការបែបនេះ ដែលមានការជាប់ទាក់ទងយ៉ាងសំខាន់ទៅនឹងសំណុំរឿងនានានាថ្ងៃអនាគត។

៣៣. ទីពីរ វិធាន ២៣(១១) នៃវិធានផ្ទៃក្នុង អាចត្រូវបានយល់ឃើញថាបានអនុញ្ញាតឱ្យតុលាការមានការបត់បែនឱ្យបានខ្លាំងជាងនេះក្នុងការផ្តល់នូវប្រាក់សំណង និងក្នុងការអនុវត្តការសម្រេចពីប្រាក់សំណងដ៏មានន័យ។ ម្យ៉ាងវិញទៀត បទបញ្ញត្តិអាចត្រូវបានយល់ឃើញដូច្នេះដែលនាំឱ្យបទបញ្ញត្តិនោះបានផ្តល់នូវការណែនាំយ៉ាងច្បាស់លាស់ អំពីនរណាដែលគួរតែផ្តល់ប្រាក់សំណង នៅពេលដែលជនជាប់ចោទដែលបានទទួលការកាត់ទោសរួចមានបំណងផ្តល់នូវប្រាក់សំណងនោះ ក៏ប៉ុន្តែបទបញ្ញត្តិនោះ*ពុំមានចែងបន្តិចណាសោះ*ពីការណែនាំអំពីថាតើ ប្រាក់សំណងត្រូវផ្តល់ឱ្យតាមរបៀបណា នៅពេលដែលទណ្ឌិតមានភាពទុរគតនោះ។ ដោយសារតែបទបញ្ញត្តិនេះមានន័យមិនច្បាស់លាស់ និងចែងពីការណែនាំតិចតួចពេក តុលាការមានសេរីភាពក្នុងការពិនិត្យអំពីស្តង់ដារនិងការអនុវត្តជាអន្តរជាតិ។ ជាការពិត នៅពេលដែលមានភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងការបកស្រាយឬការអនុវត្តវិធាននីតិវិធី ឬក្នុងករណីមានបញ្ហាចោទពាក់ព័ន្ធនឹងភាពស្របគ្នារបស់វិធានជាមួយនឹងការណែនាំតាមកម្រិតស្តង់ដារអន្តរជាតិ អាចត្រូវបានស្នើសុំនៅក្នុងវិធាននីតិវិធីនានាដែលបានបង្កើតឡើងតាមកម្រិតអន្តរជាតិ[28]។ ការបកស្រាយនេះមានលក្ខណៈកាន់តែ

---

[28] *សូមមើល* មាត្រា ៣៣ ថ្មី, ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ... ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះបូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (**នស/រកម /១០០៤/០០៦**) អាចមើលបាននៅ http://www.eccc.gov.kh/khmer/cabinet/law/3/KR_Law_as_amended_27_Oct_2004_Kh__Combination_.pdf

ស្របគ្នាទៅនឹងកាតព្វកិច្ចអន្តរជាតិនៅកម្ពុជា ចំពោះជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌។

៣៤. សិទ្ធិរបស់ជនរងគ្រោះក្នុងការទាមទារសំណង បានរកឃើញថា មានការគាំទ្រយ៉ាងរឹងមាំនៅក្នុងច្បាប់អន្តរជាតិ ដោយមិនគិតអំពីថាតើទណ្ឌិតមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីផ្តល់ជាសំណងដ៏មានប្រសិទ្ធភាពនិងគ្រប់គ្រាន់ឬគ្មាននោះទេ។ ឧទាហរណ៍ មហាសន្និបាតអង្គការសហប្រជាជាតិបានអះអាងថា រដ្ឋមានកាតព្វកិច្ច "បង្កើតកម្មវិធីថ្នាក់ជាតិសម្រាប់ការផ្តល់សំណង និងជំនួយផ្សេងទៀតដល់ជនរងគ្រោះ នៅក្នុងព្រឹត្តិការណ៍ដែលភាគីដែលទទួលខុសត្រូវចំពោះការខូចខាតដែលគួរឱ្យឈឺចាប់មិនអាច ឬមិនមានបំណងបំពេញនូវកាតព្វកិច្ចរបស់ខ្លួននោះ"[29]។ ជាការពិត រាជរដ្ឋាភិបាលកម្ពុជាមិនបានជំទាស់ទៅនឹងសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិនេះទេ[30]។ អនុលោមតាមនេះ តុលាការអាចជម្រុញទឹកចិត្តរបស់រដ្ឋាភិបាលកម្ពុជាដែលមិនដូចជាតុលាការអន្តរជាតិ(ភាវូបនីយកម្ម)ផ្សេងទៀត ដែលមានទំនាក់ទំនងពិសេសតែមួយគត់ជាមួយតុលាការនេះ ឱ្យបង្កើតនូវកម្មវិធីផ្តល់ប្រាក់សំណង ដែលឧបត្ថម្ភដោយរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ បានចែងថាទ្រព្យសម្បត្តិដែលតម្រូវតាមការប្រព្រឹត្តិបទល្មើសអាច "ប្រគល់ត្រលប់ទៅឱ្យរដ្ឋវិញ"[31]។ បញ្ញត្តិនេះបង្ហាញអំពីសេចក្តីត្រូវការក្នុងការពិនិត្យអំពីសំណង ដែលស្ថិតនៅក្រៅអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងបង្ហាញសំណងទាំងនោះថាជាកាតព្វកិច្ចរបស់រដ្ឋ។ តុលាការគួរតែជូនដំណឹងដល់រាជរដ្ឋាភិបាលកម្ពុជា អំពីសេចក្តីត្រូវការក្នុងការបង្កើតនូវមូលនិធិពិសេស និងស្នើសុំរដ្ឋាភិបាលឱ្យដាក់ផែនការរបស់ខ្លួន និងមតិយោបល់ទៅលើបញ្ហានេះកុំឱ្យហួសរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចេញសាលក្រម។

---

[29] គោលការណ៍មូលដ្ឋាន, *យោងខាងលើ* កំណត់សម្គាល់ ៣, កថាខណ្ឌ IX (១៦)។

[30] គោលការណ៍មូលដ្ឋាន, *យោងខាងលើ* កំណត់សម្គាល់ ៣, ជំពូក XI ។

[31] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (**នស/រកម/១០០៤/០០៦**) [*បន្ទាប់ពីនេះ* "ច្បាប់ស្តីពីការបង្កើត"] ជំពូក XI, មាត្រា៣៩ ។

៣៥. លើសពីនេះទៀត ប្រភពផ្សេងទៀតនៃការផ្តល់ប្រាក់ ក្រៅពីតាមរយៈរដ្ឋ គួរតែយកទៅធ្វើការពិនិត្យផងដែរ ប្រសិនបើរដ្ឋមិនអាចធ្វើការសន្មតអំពីការទទួលខុសត្រូវចំពោះប្រាក់សំណងបានទេនោះ។ លទ្ធភាពមួយ គឺការបង្កើតនូវមូលនិធិពិសេសរបស់ជនរងគ្រោះដោយស្ម័គ្រចិត្តនិងដោយឯករាជ្យ សម្រាប់គោលបំណងអនុវត្តទម្រង់បែបបទនៃសំណងសមូហភាពនិងសំណងផ្លូវចិត្ត។ មូលនិធិនេះ អាចត្រូវបានគ្រប់គ្រងតាមរយៈអង្គភាពជនរងគ្រោះ ឬអង្គភាពផ្សេងទៀត ដែលបានបង្កើតឡើងនិងបានផ្តល់សិទ្ធិអំណាចយ៉ាងពិសេស ដើម្បីធ្វើការគ្រប់គ្រងមូលនិធិនោះ និងអាចត្រូវបានឧបត្ថម្ភថវិកាតាមរយៈប្រភពខាងក្រៅ ក៏ដូចជាតាមរយៈការផ្ទេរកម្មសិទ្ធិ ដែលតម្រូវតាមបទឧក្រិដ្ឋដែលត្រូវបានរឹបអូសយករបស់ជនជាប់ចោទទៅក្នុងមូលនិធិនោះ ប្រសិនបើមានកម្មសិទ្ធិណាមួយត្រូវបានរកឃើញនោះ។ បច្ចុប្បន្ននេះអង្គភាពជនរងគ្រោះគឺជាអ្នកទំនាក់ទំនងកណ្តាល រវាងតុលាការជាមួយជនរងគ្រោះ ហេតុដូច្នេះហើយអង្គភាពជនរងគ្រោះមានតួនាទី មួយល្អបំផុតក្នុងការគ្រប់គ្រងមូលនិធិបែបនេះ។ លើសពីនេះទៀត ការបង្កើតមូលនិធិស្ម័គ្រចិត្តតាមរយៈអង្គភាពជនរងគ្រោះ នឹងបញ្ចៀសបាននូវសេចក្តីត្រូវការក្នុងការបង្កើតផ្នែកមួយទៀតរបស់តុលាការ ដែលនឹងធ្វើឲ្យអស់ធនធានច្រើន។

៣៦. ធ្លាប់មានហេតុការណ៍ជាអន្តរជាតិស្តីពីការបង្កើតមូលធិនិបែបនេះដែរ។ ច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) បានរួមបញ្ចូលយ៉ាងប្រាកដនូវលទ្ធភាពសម្រាប់ជនរងគ្រោះក្នុងការទទួលបាននូវប្រាក់សំណងពីបទឧក្រិដ្ឋ ដែលត្រូវបានផ្តន្ទាទោស[32]។ ច្បាប់លក្ខន្តិកៈនេះក៏បានទទួលស្គាល់ថា ភាគច្រើននៃទណ្ឌិតទាំងអស់នោះគឺជាជនក្រីក្រ ឬគ្មានទ្រព្យសម្បត្តិអ្វីឡើយ និងបានបង្កើតនូវមូលនិធិពិសេសមួយ“សម្រាប់ជាប្រយោជន៍របស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មនានា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ” និង “របស់ក្រុមគ្រួសាររបស់ជនរងគ្រោះទាំងនេះ”[33]។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិអាចបង្គាប់ឲ្យមានការផ្ទេរប្រាក់ពិន័យ ឬកម្មសិទ្ធិដែលរឹបអូសបានណាមួយចូលទៅក្នុងមូលនិធិនេះក្នុងករណី និងក្នុងពេលដែលអាចធ្វើបាន។

---

[32] មហាសន្និបាទអង្គការសហប្រជាជាតិ *លក្ខន្តិកៈក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ* (វិសោធនកម្មលើកចុងក្រោយនៅខែមករា ឆ្នាំ២០០២) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨, A/CONF. 183/9 [*បន្ទាប់ពីនេះ* “លក្ខន្តិកៈក្រុងរ៉ូម”] មាត្រា៧៥។

[33] លក្ខន្តិកៈក្រុងរ៉ូម, មាត្រា ៧៩។

៣៧. ឧទាហរណ៍មួយផ្សេងទៀត អាចត្រូវបានរកឃើញផងដែរនៅក្នុងមូលនិធិដែលគ្រប់គ្រងដោយអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះដោយសារទារុណកម្ម ដែលទទួលនូវការចូលរួមវិភាគទានដោយស្ម័គ្រចិត្តពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលឯកជន ដើម្បីចែកចាយទៅអង្គការក្រៅរដ្ឋាភិបាលនានា ដែលផ្ដល់ជំនួយមនុស្សធម៌ដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគាត់[34]។

៣៨. ឧទាហរណ៍ក្នុងស្រុកនានា រួមមានប្រព័ន្ធច្បាប់ក្នុងស្រុកកាណាដានិងចក្រភពអង់គ្លេស ដែលផ្ដល់មូលនិធិពិសេសដល់ជនរងគ្រោះនានា តាមរយៈច្បាប់ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមរបស់ខ្លួន។ មូលនិធិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទទួលយកនូវការបរិច្ចាគនានា ដែលការបរិច្ចាគទាំងនោះត្រូវបានដាក់ចូលក្នុងមូលនិធិសម្រាប់ជាសំណងរបស់ជនរងគ្រោះ[35]។ នៅប្រទេសម៉ាឡាវី អ្នកឧបត្ថម្ភបានបង្កើតមូលនិធិនានា ដើម្បីផ្ដល់នូវការផ្សព្វផ្សាយអប់រំ និងដើម្បីរៀបចំព្រឹត្តិការណ៍នានាសម្រាប់ប្រជាជនមូលដ្ឋាន។ ទោះបីជាមូលនិធិនានាមិនបានផ្ដល់នូវសំណងខូចខាតដល់ជនរងគ្រោះ នៃអំពើរំលោភបំពានសិទ្ធិមនុស្ស ឬក្រុមគ្រួសាររបស់ពួកគេក៏ដោយ ការផ្សព្វផ្សាយអប់រំបានលើកឡើងនូវការយល់ដឹងក្នុងចំណោមប្រជាជន និងបានផ្ដល់ដល់ជនរងគ្រោះនូវវេទិកាមួយដែលអាចឱ្យពួកគេនិយាយនូវរឿងរ៉ាវរបស់ខ្លួនបាន[36]។ មូលនិធិសំណងខូចខាតពិតមានលក្ខណៈសំខាន់ប្រាកដណាស់ អាស្រ័យដោយការបង្កើតនូវការរាប់អានគ្នាជាសមូហភាព និងការទុកចិត្តគ្នានៅក្នុងសហគមន៍។

៣៩. ច្បាស់ណាស់ថា យ៉ាងហោចណាស់ក៏តុលាការនេះស្ថិតនៅក្នុងតួនាទីពិសេសតែមួយគត់ ដែលតុលាការអាចបង្គាប់ឱ្យអង្គភាពជនរងគ្រោះ បង្កើតនូវមូលនិធិពិសេសស្ម័គ្រចិត្តមួយ

---

[34] ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស, *មូលនិធិស្ម័គ្រចិត្តអ.ស.ប សម្រាប់ជនរងគ្រោះនៃទារុណកម្ម*, http://www.ohchr.org/EN/Issues/Pages/TortureFundMain.aspx (*ចូលទស្សនាចុងក្រោយ* ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៩)។

[35] Carla Ferstman, របបសំណងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ Practical Consideration, (2002) 15 *Leiden Journal of International Law*, ទំព័រ៦៨៥។

[36] Diana Cammack, "សំណងនៅក្នុង Malawi" *នៅក្នុង* Pablo De Greiff, *កម្រងឯកសារសំណង, យោងខាងលើ* កំណត់សម្គាល់ ២៥, ទំព័រ ២២៨។

និងតាមរយៈសាលក្រមសម្រេចផ្តល់ប្រាក់សំណងរបស់ខ្លួន តុលាការមានតួនាទីជម្រុញឱ្យបានខ្លាំងក្លាដល់ព្រះរាជាណាចក្រកម្ពុជា ឱ្យធ្វើការនាំមុខគេក្នុងការផ្តល់នូវប្រាក់សំណងដល់ជនរងគ្រោះ ក៏ដូចជាធ្វើសេចក្តីរាយការណ៍ជូនមកតុលាការវិញអំពីការរីកចម្រើនទាំងឡាយណាដែលពាក់ព័ន្ធនឹងមូលនិធិបែបនេះ។ លើសពីនេះទៀត តុលាការគួរតែដើរតួនាទីឱ្យបានជាក់ស្តែងនៅក្នុងការធានាថា គម្រោងការនៃការបង្កើតដ៏ចាំបាច់នេះត្រូវបានបង្កើតឡើងដើម្បីធានាថា មូលនិធិពិសេសត្រូវបានគ្រប់គ្រងប្រកបដោយតម្លាភាព ប្រសិទ្ធភាព ទន់ភ្លន់ និងឯករាជ្យ។

## VI. ការប្រតិបត្តិនិងការអនុវត្តការបង្គាប់ឲ្យផ្តល់នូវប្រាក់សំណងនានា

៤០. វិធាន ១១៣(៣) នៃវិធានផ្ទៃក្នុងបានចែងថា សហព្រះរាជអាជ្ញា "អាចសុំជំនួយពីអាជ្ញាធរអនុវត្តច្បាប់ដើម្បីធានាដល់ការអនុវត្តទោស"។ នៅពេលដែលសកម្មភាពនៃការអនុវត្តពាក់ព័ន្ធនឹងលក្ខណៈព្រហ្មទណ្ឌនៃសាលក្រមស្ថាពរ មើលឃើញដល់វចនាសម្ព័ន្ធព្រហ្មទណ្ឌ និងឧក្រិដ្ឋកម្មដែលមានស្រាប់ពីមុនរបស់រដ្ឋាភិបាលកម្ពុជា កំពុងតែត្រូវបានប្រើប្រាស់នោះ វិធានផ្ទៃក្នុងបានចែងពាក់ព័ន្ធតែនឹងសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីថា "ការអនុវត្តការផ្តល់សំណងត្រូវធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់ដើមបណ្តឹងរដ្ឋប្បវេណី"[37]។

៤១. នៅពេលដែលតុលាការលើកឡើងច្បាស់លាស់ អំពីទម្រង់បែបបទនៃការអនុវត្តការផ្តល់សំណងដែលត្រូវផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការគួរតែលើកឡើងច្បាស់លាស់អំពីតួអង្គដែលត្រូវទទួលខុសត្រូវការអនុវត្តការផ្តល់សំណងនោះផង។ តុលាការត្រូវធានាផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងតវ៉ាចំពោះការមិនអនុវត្តប្រឆាំងនឹងតួអង្គដែលទទួលខុសត្រូវនោះទៅតុលាការ ដែលបន្សល់ទុកនូវយន្តការអនុវត្តដំបូងនៅក្នុងពេលអត្ថិភាពរបស់ខ្លួន។ ជាងនេះទៀត បទបញ្ញត្តិត្រូវតែធ្វើឡើងដើម្បីធានាដល់ការអនុវត្តការផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីបន្តទៀត និងការត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាព ព្រមទាំងការអនុវត្តនីតិវិធីហួសពីអត្ថិភាព របស់តុលាការ។

---

[37] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ១១៣(១)។

## VII. សន្និដ្ឋាន

៤២. ការវិនាសហិនហោចដែលបង្កឡើងដោយឧក្រិដ្ឋកម្មខ្មែរក្រហម និងជាពិសេសអ្នកទាំងឡាយនៅមន្ទីរ ស-២១ បានបង្កើតជាផលវិបាកយ៉ាងធំធេងនិងមានរយៈពេលវែងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី និងសង្គមកម្ពុជាជាទូទៅ។ ការផ្ដល់នូវភាពយុត្តិធម៌ផ្នែកសំណងដ៏មានន័យដែលជាលទ្ធផលនៃអំពើកំណាចឃោរឃៅខ្មែរក្រហម គឺពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណដំណោះស្រាយនានាដែលជាការឆ្លើយតបទៅនឹងសិទ្ធិ សេចក្ដីត្រូវការ និងអាទិភាពនៃផលប្រយោជន៍ដែលបានកំណត់ ពោលគឺដើមបណ្ដឹងរដ្ឋប្បវេណី។

៤៣. ដោយបង្ហាញឱ្យឃើញពីអលទ្ធភាពក្នុងការដោះស្រាយឱ្យបានពេញលេញ ទៅលើការវិនាសខូចខាតដែលបានបង្កឡើង ចំនួនត្រឹមត្រូវនៃជនរងគ្រោះដែលពាក់ព័ន្ធ និងគម្លាតគ្នាក្នុងបទពិសោធន៍និងសេចក្ដីត្រូវការរបស់ជនរងគ្រោះ មានការយល់ឃើញជាទូទៅមួយថា ការផ្ដល់នូវប្រាក់សំណងដ៏មានន័យនៅក្នុងបរិបទសង្គមកម្ពុជា គួរតែមានលក្ខណៈសមូហភាព និងមានលក្ខណៈផ្លូវចិត្ត។

៤៤. ដំណើរការនៃការបង្កើតនិងការអនុវត្តការផ្ដល់សំណងឱ្យបានជោគជ័យ តម្រូវឱ្យមានការពិចារណាយ៉ាងយកចិត្តទុកដាក់ ទៅលើសំណើនានារបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងគោលបំណងនៃកម្មវិធីផ្ដល់សំណង[38]។ តុលាការនេះគួរព្យាយាមបង្កើននូវផលប៉ះពាល់នៃសិទ្ធិអំណាចផ្ដល់សំណងរបស់ខ្លួនឱ្យបានខ្លាំងក្លា តាមរយៈការធ្វើកិច្ចការជាមួយរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលដែលបានបង្កើតឡើង ដើម្បីផ្ដល់នូវទម្រង់បែបបទដែលសមស្របបំផុតនៃការផ្ដល់សំណងជាសមូហភាព និងសំណងផ្លូវចិត្តដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។

---

[38] M. Brinton Lykes, Marcie Mersky, "សំណង និងសុខភាពផ្លូវចិត្ត៖ អន្តរាគមន៍ផ្នែកចិត្តសង្គម ឆ្ពោះទៅរកការផ្សះផ្សាស្រុះស្រួល ទំនាក់ទំនងមនុស្ស និងការភ្ជាប់ការពិតនៃសង្គមឡើងវិញ"។ *នៅក្នុង* Pablo De Greiff, *កូនសៀវភៅនៃសំណង, យោងខាងលើ* កំណត់សម្គាល់ ២៥, ទំព័រ៦០៤។

៤៥. ស្របជាមួយនឹងការលើកឡើងខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បាន ស្នើដោយក្តីគោរពសុំឲ្យអង្គជំនុំជម្រះសាលាដំបូង យ៉ាងហោចណាស់ផ្តល់ដល់ដើមបណ្តឹង រដ្ឋប្បវេណីដូចខាងក្រោម:

- ការចងក្រង និងការផ្សព្វផ្សាយសេចក្តីថ្លែងសុំអភ័យទោសដែលធ្វើឡើងដោយ ជនជាប់ចោទ ឌុច នៅក្នុងសវនាការ ដែលបានទទួលស្គាល់នូវការលំបាក និងការ ឈឺចាប់របស់ជនរងគ្រោះ រួមទាំងយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើ ការសូមអភ័យទោសទាំងអស់នេះ។
- ការទទួលបាននូវការថែទាំសុខភាពដោយឥតគិតថ្លៃ រួមទាំងការថែទាំទាំងផ្លូវចិត្ត និងរូបរាងកាយ ព្រមទាំងការដឹកជញ្ជូនទៅកាន់កន្លែងថែទាំសុខភាពទាំងនោះ។
- ការផ្តល់ថវិការដល់កម្មវិធីសិក្សាអប់រំ ទាំងនៅសាលានិងនៅសារមន្ទីរនានា ដែលជូនដំណឹងដល់ប្រជាជនកម្ពុជាអំពីឧក្រិដ្ឋកម្មនានា ដែលបានកើតឡើងក្នុង របបខ្មែរក្រហម និងជាពិសេសនៅមន្ទីរ ស-២១។
- ការបង្កើតនូវបូជនីយដ្ឋាន វត្ត និងរបងវត្ត ទាំងនៅមន្ទីរ ស-២១ (បឹងជើងឯក និងគុកព្រៃស)ក៏ដូចជានៅក្នុងសហគមន៍មូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។
- រួមបញ្ចូលនូវឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងសំណុំរឿងនេះ នៅក្នុងសាលក្រមស្ថាពរ រួមទាំងការគូសបញ្ជាក់ពាក់ព័ន្ធនឹងទំនាក់ទំនងរបស់ ពួកគាត់ជាមួយនឹងមន្ទីរ ស-២១។

៤៦. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសង្កត់ធ្ងន់ថា សំណើសុំទាំងអស់ខាងលើ គឺជា សំណើសុំដ៏តិចតួចដែលស្នើដោយដើមបណ្តឹងរដ្ឋប្បវេណី និងស្វាគមន៍នូវរាល់ការផ្តល់ សំណងបន្ថែមទៀតដែលតុលាការយល់ឃើញថាសមរម្យ និងដែលស្របគ្នាជាមួយនឹង សំណើដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារតែនេះជាការដាក់រួមគ្នា របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗសូមរក្សា

សិទ្ធិក្នុងការធ្វើការទាមទារសំណងបន្ថែមទៀត នៅក្នុងសារណាចុងក្រោយរបស់ខ្លួនម្នាក់ៗ ដូចដែលបានណែនាំដោយអង្គជំនុំជម្រះសាលាដំបូង[39]។

៤៧. ប្រសិនបើជនជាប់ចោទដែលបានទទួលនូវការកាត់ទោស មិនអាចរ៉ាប់រងតាមការកំណត់តម្លៃនៃការផ្តល់ប្រាក់សំណងដែលបានលើកឡើងខាងលើនោះទេ តុលាការអាចធានាថារដ្ឋាភិបាលកម្ពុជាអនុវត្តនូវការផ្តល់សំណងនោះយោងតាមកាតព្វកិច្ចរបស់រដ្ឋ ឬក៏អង្គភាពជនរងគ្រោះអនុវត្តនូវការផ្តល់សំណងនោះ តាមរយៈការបង្កើតមូលនិធិពិសេសតាមការស្ម័គ្រចិត្តមួយ។

សូមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ
ដើមបណ្តឹងរដ្ឋប្បវេណី

ចុះហត្ថលេខានៅទីក្រុងភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩

កញ្ញា ទី ស្រ៊ីនណា — លោក Alain Werner

លោក Karim A.A. Khan — លោកស្រី Brianne McGonigle

---

[39] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ, សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សា ដេញដោល ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, កថាខណ្ឌ៥។ ("សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ត្រូវបញ្ជាក់ ... ការទាមទារសំណងរបស់ពួកគាត់")។

E159/3

០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

លោក គង់ ពិសី

លោក ហ៊ុង គីមសួន

លោក Pierre-Oliver SUR

លោក យ៉ុង ផានិត

លោកស្រី Silke STUDZINSKY

លោក គីម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោកស្រី Christine MARTINEAU

លោកស្រី Fabienne Trusses NAPROUS

លោកស្រី Annie DELAHAIE

លោកស្រី Elisabeth RABESANDRATANA